ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១៣.....សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀតស្តីពីការនាំចេញ និងនាំចូល

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.-

បុគ្គលដែលចូលរួម ឬពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល ត្រូវតែរក្សាឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត រាប់បញ្ចូលទាំង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ព័ត៌មានជាសណ្ឋានអេឡិចត្រូនិកដែលត្រឹមត្រូវ និងគ្រប់គ្រាន់ដែលពាក់ព័ន្ធនឹងការនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិកថាខណ្ឌទី ១ មាត្រា ៥១ នៃច្បាប់ស្តីពីគយ ។

បុគ្គលទាំងនេះ និងតំណាងរបស់ខ្លួន មានកាតព្វកិច្ចផ្តល់បង្ហាញនូវឯកសារ បញ្ជី គណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់របស់គយស្របតាមបញ្ញត្តិកថាខណ្ឌទី ១ មាត្រា ៥២ នៃច្បាប់ស្តីពីគយ ។

បញ្ញត្តិនៃប្រការនេះ ពុំអនុវត្តចំពោះបុគ្គលនានាដែលនាំចូល ឬនាំចេញទំនិញសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬសម្រាប់សំណូមពរដែលគ្មានលក្ខណៈពាណិជ្ជកម្ម ឬលក្ខណៈស្ថាប័ន ។

**ប្រការ ២.-**

បុគ្គលដែលចូលរួម ឬពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល រួមមានអ្នកនាំចូល អ្នកនាំចេញ ជើងសារគយ ប្រតិបត្តិករកន្លែងសន្និធិគយបណ្តោះអាសន្ននិងកណ្តាគារគយមានដែនកំណត់ ប្រតិបត្តិករដឹកជញ្ជូន តំណាងស្របច្បាប់របស់អ្នកនាំចូល ឬនាំចេញ និងបណ្តាភាគីពាក់ព័ន្ធផ្សេងទៀតដែលចូលរួមក្នុងការនាំចេញ ឬនាំចូល ។

**ប្រការ ៣.-**

ឯកសារ គឺជាឯកសារតាមទម្រង់ណាមួយ ទោះជាមាន ឬគ្មានចុះហត្ថលេខា ឬចុះអាទិសង្កេត ឬធ្វើយថាភូតដោយអ្នកតាក់តែង និងរាប់បញ្ចូលទាំង ៖

- ទម្រង់ណាមួយដែលសរសេរលើសម្ភារៈ

- ព័ត៌មានថតទុក បញ្ជូន ឬរក្សាទុកដោយមធ្យោបាយនានា ដូចជាឧបករណ៍ថត កុំព្យូទ័រ ឬឧបករណ៍ផ្សេងទៀត និងសម្ភារៈដែលយកចេញពីព័ត៌មានទាំងនេះ ។

- ស្លាក ឬសញ្ញាសម្គាល់ផ្សេងទៀត ឬការសរសេរដែលភ្ជាប់នឹងវត្ថុអ្វីមួយ ឬសម្ភារៈជាភាគណាមួយនៃវត្ថុនោះ ។

- សៀវភៅ ផែនទី ប្លង់ ក្រាហ្វ ឬគំនូរ

- រូបថត ហ្វីល ខ្សែអាត់ ឬឧបករណ៍ផ្សេងទៀតដែលផ្ទុកនូវ រូបភាព ហើយមានលទ្ធភាពអាចធ្វើការផ្តិតចម្លងបាន ។

**ប្រការ ៤.-**

ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងៗដែលតម្រូវឱ្យថែរក្សាក្រោមបញ្ញត្តិមាត្រា ៩១ នៃច្បាប់ស្តីពីគយ រួមមាន ៖

១. ឯកសារដឹកជញ្ជូន និងឯកសារបញ្ចេញទំនិញពីគយ រួមមាន ៖

- ប្រតិវេទន៍គយ និងបង្កាន់ដៃបង់ប្រាក់
- វិក្កយប័ត្រ និងបញ្ជីវេចខ្ចប់ទំនិញ
- និវេទន៍ប័ណ្ណទំនិញ និងអញ្ញត្តិប័ណ្ណរួមទាំងអញ្ញត្តិប័ណ្ណផ្លូវអាកាស និងឯកសារដឹកជញ្ជូនផ្សេងទៀត
- អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនប័ត្រប្រភពដើមដែលតម្រូវ
- កំណត់សម្គាល់នានាពាក់ព័ន្ធនឹងការប្រគល់-ទទួលទំនិញ
- ឯកសារពាក់ព័ន្ធនឹងការលើកលែង ឬការលើកលែងជាភាគនូវពន្ធ និងអាករ ការបង្វិលសងវិញ ការបន្ធូរបន្ថយ បន្ទុក និងកម្រៃ រាប់បញ្ចូលទាំងកម្រៃដើងសារគយ បន្ទុកចំណាយលើកំពង់ផែ និងបន្ទុកចំណាយលើភ្នាក់ងារផ្សេងទៀត
- ឯកសារពាក់ព័ន្ធផ្សេងទៀត ។

២. កំណត់ត្រាធុរកិច្ចរួមមាន ៖

- កំណត់ត្រា និងកិច្ចសន្យាទិញលក់
- កិច្ចព្រមព្រៀង និងការបញ្ជាទិញ
- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្រៃសួយសារ ថ្លៃទំនិញ និងការជានា
- របាយការណ៍ និងកំណត់ត្រាឃ្លាំងរួមទាំងបញ្ជីសារពើភ័ណ្ឌ
- របាយការណ៍ និងកំណត់ត្រាផលិតកម្ម
- កិច្ចសន្យាជំនួយបច្ចេកទេស
- កិច្ចសន្យាសេវាកម្មដើងសារ និងកំណត់ត្រានៃការទូទាត់
- លិខិតឆ្លើយឆ្លង ឬលិខិតទាក់ទងធុរកិច្ចរវាងអ្នកនាំចូល ឬអ្នកនាំចេញ និងភាគីពាក់ព័ន្ធផ្សេងទៀត

- ព័ត៌មាន និងកំណត់ត្រាពាក់ព័ន្ធផ្សេងទៀត ។

៣. បញ្ជី និងកំណត់ត្រាគណនេយ្យរួមមាន ៖

- សៀវភៅធំ និងរបាយការណ៍គណនេយ្យ
- កំណត់ត្រានៃការទូទាត់ និងបង្កាន់ដៃ
- របាយការណ៍ពីការចំណេញ ខាត
- តារាងតុល្យការ
- លិខិតឥណទាន ពាក្យសុំលិខិតឥណទាន លិខិតធនាគារ
- កំណត់ត្រាការផ្ទេរមូលនិធិ ដើមទុនតាមមធ្យោបាយអេឡិចត្រូនិច
- ចម្ងងការនានាតាមរយៈប័ណ្ណឥណទាន
- របាយការណ៍ធនាគាររួមទាំងកំណត់ត្រាមូលប្បទានប័ត្រ
- របាយការណ៍សវនកម្មគ្រប់ប្រភេទ
- លិខិតឆ្លើយឆ្លង កំណត់ត្រា និងបញ្ជីពាក់ព័ន្ធផ្សេងទៀត

៤. ព័ត៌មានផ្សេងទៀតរួមមាន ៖

- គំនូសតាង និងលេខសម្គាល់គណនី សៀវភៅណែនាំគណនេយ្យ និងឯកសារពាក់ព័ន្ធនឹងប្រព័ន្ធ និងកម្មវិធី ដែលរៀបរាប់ពីប្រព័ន្ធគណនេយ្យដែលប្រើប្រាស់ដោយបុគ្គលដែលចូលរួម ឬពាក់ព័ន្ធនឹងការនាំចេញ និងនាំចូលទំនិញ ។

- ឯកសារ បញ្ជី ថាស ខ្សែអាត់ ហ្វីល ឬឧបករណ៍ផ្សេងទៀតដែលមានផ្ទុកព័ត៌មានដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ។

**ប្រការ ៥.-**

បញ្ជី កំណត់ត្រា និងព័ត៌មានដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ ត្រូវរក្សាទុករយៈពេល ដប់ (១០) ឆ្នាំ នៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកាប្រតិវេទន៍គយពាក់ព័ន្ធ ឬកាលបរិច្ឆេទដែលឯកសារខាងលើត្រូវបានធ្វើឡើង ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៧
- សភាពាណិជ្ជកម្មកម្ពុជា " ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ